# NAPLAN តាមក្រដាស – ព័ត៌មានសម្រាប់មាតាបិតា និងអ្នកថែទាំ

Khmer

NAPLAN
NATIONAL ASSESSMENT PROGRAM
Literacy and Numeracy

2019

## ហេតុអ្វីបានជាសិស្សធ្វើតេស្ត NAPLAN?

កម្មវិធីជាតិវាយតម្លៃសមត្ថភាពសិក្សា – អក្ខរកម្មនិងលេខនព្វន្ត (NAPLAN) វាយតម្លៃបំណិនអក្ខរកម្មនិងលេខនព្វន្ត ដែលសំខាន់ចាំបាច់សម្រាប់កុមារ រាល់រូប ក្នុងការវិវឌ្ឍតាមរយៈសាលារៀននិងការរស់នៅ។

សិស្សថ្នាក់ទី 3, 5, 7 និង 9 ចូលរួមក្នុងតេស្ត NAPLAN ប្រចាំឆ្នាំ ក្នុងផ្នែកអាន សរសេរ និងចំណេះដឹងទូទៅនៃភាសា (ប្រកបអក្សរ វេយ្យាករណ៍ និងវណ្ណយុត្តិ) និងលេខនព្វន្ត។

តេស្តទាំងនេះផ្តល់ឱ្យមាតាបិតានិងសាលារៀននូវការយល់ដឹងថា តើសិស្សនីមួយៗកំពុងបំពេញលទ្ធផលសិក្សាយ៉ាងណាដែរនៅពេលធ្វើតេស្ត។ NAPLAN គឺគ្រាន់តែជាទិដ្ឋភាពមួយនៃដំណើរការវាយតម្លៃនិងធ្វើរបាយការណ៍របស់សាលារៀនប៉ុណ្ណោះ - វាមិនជំនួសឱ្យការវាយតម្លៃជាបន្តបន្ទាប់ដែលធ្វើដោយគ្រូបង្រៀនអំពីការបំពេញលទ្ធផលសិក្សារបស់សិស្សឡើយ។

NAPLAN ក៏ផ្តល់ឱ្យសាលារៀន អាជ្ញាធរអប់រំ និងរដ្ឋាភិបាលផងដែរនូវព័ត៌មានអំពីថាតើកម្មវិធីអប់រំកំពុងដំណើរការយ៉ាងណាដែរ និងថាតើពលរដ្ឋអូស្ត្រាលីវ័យក្មេងទាំងឡាយកំពុងបំពេញបាននូវលទ្ធផលអប់រំដ៏សំខាន់ក្នុងផ្នែកអក្ខរកម្មនិងលេខនព្វន្តដែរឬទេ។

## តើនឹងធ្វើតេស្តអំពីអ្វីខ្លះ?

NAPLAN វាយតម្លៃបំណិនអក្ខរកម្មនិងលេខនព្វន្តដែលសិស្សកំពុងសិក្សាតាមរយៈកម្មវិធីសិក្សាប្រក្រតីនៃសាលារៀនរបស់ខ្លួន។ អាជ្ញាធរអប់រំរបស់រដ្ឋនិងមិនមែនរបស់រដ្ឋទាំងអស់បានរួមចំណែកដល់ការបង្កើតសម្ភារឯកសារ NAPLAN ។

សូមអានសំណួរ NAPLAN ជាឧទាហរណ៍នៅឯ **nap.edu.au**

## តើខ្ញុំអាចជួយកូនខ្ញុំត្រៀមខ្លួនសម្រាប់ NAPLAN តាមវិធីណា?

ជួយកូនលោកអ្នកត្រៀមខ្លួនតាមរយៈការផ្តល់ទំនុកចិត្តជាថ្មីដល់កូនថា NAPLAN គ្រាន់តែជាផ្នែកមួយនៃកម្មវិធីសាលារៀនរបស់កូនប៉ុណ្ណោះ និងតាមរយៈការរំលឹកកូននៅថ្ងៃធ្វើតេស្តឱ្យគ្រាន់តែខិតខំអស់ពីសមត្ថភាពរបស់ខ្លួនប៉ុណ្ណោះ។ គ្រូបង្រៀននឹងធានាបន្សាំសិស្សឱ្យស្គាល់ដឹងប្រភេទសំណួររបស់តេស្ត ហើយនឹងផ្តល់ជំនួយនិងការណែនាំសមស្រប។

ACARA មិនស្នើឱ្យមានការត្រៀមខ្លួនហួសហេតុមែនទែនសម្រាប់ NAPLAN ឬការប្រើប្រាស់សេវាកម្មនៃអ្នកផ្តល់ការហ្វឹកហ្វឺនឡើយ។

NAPLAN គឺអំពីការវាយតម្លៃការរីកចម្រើននៃការសិក្សាក្នុងផ្នែកអក្ខរកម្មនិងលេខនព្វន្ត។

## ការចូលរួមក្នុង NAPLAN

សិស្សទាំងអស់ដែលរៀននៅថ្នាក់ទី 3, 5, 7 និង 9 ត្រូវបានរំពឹងថា នឹងចូលរួមក្នុងការធ្វើតេស្តវាយតម្លៃ NAPLAN ប្រចាំឆ្នាំ។

សិស្សមានពិការភាពអាចមានសិទ្ធិទទួលការកែតម្រូវដែលឆ្លុះបញ្ចាំងជំនួយដែលផ្តល់ឱ្យជាធម្មតា សម្រាប់ការវាយតម្លៃនៅថ្នាក់រៀន។ លោកអ្នកគួរពិភាក្សាជាមួយគ្រូបង្រៀនរបស់កូនលោកអ្នកជាដំបូងសិន អំពីការប្រើកំណែតម្រូវពិការភាពណាមួយសម្រាប់កូនលោកអ្នក។

ការលើកលែងជាផ្លូវការអាចផ្តល់ឱ្យសិស្សមានពិការភាព ដែលរឹតត្បិតយ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពសិស្សទាំងនោះ ដើម្បីចូលរួមក្នុងការវាយតម្លៃនេះ ឬសម្រាប់សិស្សដែលទើបមកដល់ប្រទេសអូស្ត្រាលី ហើយមានសាវតារមិននិយាយអង់គ្លេស។

នាយកសាលារបស់កូនលោកអ្នក និងអាជ្ញាធរគ្រប់គ្រងតេស្តប្រចាំតំបន់របស់លោកអ្នក អាចផ្តល់ជូនលោកអ្នកនូវព័ត៌មានបន្ថែមអំពីការផ្តល់ឱ្យជាពិសេស ឬអំពីដំណើរការដែលត្រូវការសម្រាប់ទទួលការលើកលែងជាផ្លូវការ។

## តើកូនខ្ញុំនឹងធ្វើតេស្ត NAPLAN តាមក្រដាស ឬតាមអ៊ីនឡាញ?

នៅឆ្នាំ 2019 នេះ កូនលោកអ្នកនឹងធ្វើតេស្ត NAPLAN តាមក្រដាស។

ប៉ុន្តែ កុមារនៅតាមសាលារៀនឯទៀតនៅក្នុងប្រទេសអូស្ត្រាលីនឹងធ្វើតេស្ត NAPLAN តាមអនឡាញនៅឆ្នាំនេះ។ រដ្ឋមន្ត្រីអប់រំថ្នាក់សហព័ន្ធ រដ្ឋ និងដែនដី បានយល់ព្រមថា សាលារៀនទាំងអស់នឹងប្តូរទៅកាន់អនឡាញមិនឱ្យហួសពីឆ្នាំ 2020 ឡើយ។ អាជ្ញាធរអប់រំរដ្ឋនិងដែនដីនឹង សម្រេចនូវពេលដែលសាលារៀនរបស់ខ្លួនប្តូរទៅកាន់អនឡាញ។

ដោយសារតែសិស្សត្រូវបានវាយតម្លៃលើខ្លឹមសារកម្មវិធីសិក្សាផ្នែកអក្ខរកម្មនិងលេខនព្វន្តដូចគ្នា ដោយមិនគិតអំពីថាតើសិស្សធ្វើតេស្តតាមអនឡាញឬតាមក្រដាសទេនោះ ដូច្នេះលទ្ធផលសម្រាប់ទម្រង់ទាំងពីរនេះនឹងត្រូវបានរាយការណ៍តាមរង្វាស់ខ្នាតវាយតម្លៃ NAPLAN ដូចគ្នា។ ដើម្បីទទួលព័ត៌មានបន្ថែមអំពី NAPLAN តាមអនឡាញ សូមបើកមើលនៅឯ **nap.edu.au**

NAP NATIONAL ASSESSMENT PROGRAM

acara AUSTRALIAN CURRICULUM, ASSESSMENT AND REPORTING AUTHORITY

## តើមានអ្វីកើតឡើងបើកូនខ្ញុំមិនទៅសាលារៀននៅថ្ងៃធ្វើតេស្ត?

នៅពេលមានលទ្ធភាព សាលារៀនអាចរៀបចំឱ្យសិស្សរៀងខ្លួនទាំងឡាយដែលមិនទៅសាលារៀននៅពេលធ្វើតេស្ត ធ្វើតេស្តដែលខកខាននៅពេលមួយទៀតក្នុងអំឡុងសប្តាហ៍ធ្វើតេស្ត។

សិស្សនីមួយៗមិនត្រូវបានអនុញ្ញាតឱ្យធ្វើតេស្តនៅក្រោយថ្ងៃសុក្រ ទី 17 ឧសភា 2019 ឡើយ។

## តារាងពេលវេលាធ្វើតេស្ត NAPLAN ឆ្នាំ 2019

| | អង្គារ<br>14 ឧសភា | ពុធ<br>15 ឧសភា | ព្រហស្បតិ៍<br>16 ឧសភា |
|---|---|---|---|
| ថ្នាក់ទី 3 | ចំណេះ ដឹងភាសាទូទៅ<br>45 នាទី<br>........................<br>ការសរសេរ<br>40 នាទី | ការអាន<br>45 នាទី | លេខនព្វន្ត<br>45 នាទី |
| ថ្នាក់ទី 5 | ចំណេះ ដឹងភាសាទូទៅ<br>45 នាទី<br>........................<br>ការសរសេរ<br>40 នាទី | ការអាន<br>50 នាទី | លេខនព្វន្ត<br>50 នាទី |
| ថ្នាក់ទី 7 | ចំណេះ ដឹងភាសាទូទៅ<br>45 នាទី<br>........................<br>ការសរសេរ<br>40 នាទី | ការអាន<br>65 នាទី | លេខនព្វន្ត<br>65 នាទី |
| ថ្នាក់ទី 9 | ចំណេះ ដឹងភាសាទូទៅ<br>45 នាទី<br>........................<br>ការសរសេរ<br>40 នាទី | ការអាន<br>65 នាទី | លេខនព្វន្ត<br>65 នាទី |

## តើលទ្ធផលបំពេញការសិក្សារបស់កូនខ្ញុំត្រូវបានវាស់វែងតាមរបៀបណា?

លទ្ធផលបំពេញការសិក្សារបស់សិស្សនីមួយៗត្រូវបានបង្ហាញនៅលើរង្វាស់ខ្នាតជាតិសម្រេចបានសម្រាប់តេស្តនីមួយៗ។ លទ្ធផលនៅតាមស្តង់ដារជាតិអប្បបរមាបង្ហាញថា សិស្សបានបង្ហាញឱ្យឃើញបំណិនអក្ខរកម្មនិងលេខនព្វន្តដែលចាំបាច់ដើម្បីចូលរួមពេញលេញក្នុងកម្រិតថ្នាក់នោះ។

សាលារៀនរបស់កូនលោកអ្នកនឹងចេញរបាយការណ៍ NAPLAN សម្រាប់សិស្សនីមួយៗនៅពេលក្រោយមកទៀតនៅក្នុងឆ្នាំដដែល។ បើលោកអ្នកមិនបានទទួលរបាយការណ៍មួយទេ លោកអ្នកគួរទាក់ទងសាលារៀនរបស់កូនលោកអ្នក។

## តើលទ្ធផលនៃតេស្ត NAPLAN ត្រូវបានប្រើយ៉ាងណាដែរ?

- សិស្សនិងមាតាបិតាអាចប្រើលទ្ធផលនីមួយៗដើម្បីពិភាក្សាការរីកចម្រើនជាមួយគ្រូបង្រៀន។
- គ្រូបង្រៀនប្រើលទ្ធផលដើម្បីជួយគាត់ក្នុងការរកមើលដឹងសិស្សទាំងឡាយដែលនឹងទទួលប្រយោជន៍ពីកិច្ចការរឹតតែលំបាក ឬពីជំនួយបន្ថែម។
- សាលារៀនប្រើលទ្ធផលដើម្បីរកមើលដឹងចំណុចខ្លាំងនិងផ្នែកដើម្បីកែលំអនៅក្នុងកម្មវិធីបង្រៀន និងដើម្បីកំណត់គោលដៅនៃអក្ខរកម្មនិងលេខនព្វន្ត។
- ប្រព័ន្ធសាលារៀនប្រើលទ្ធផលដើម្បីពិនិត្យឡើងវិញនូវបណ្តាកម្មវិធីនិងជំនួយដែលផ្តល់ទៅឱ្យសាលារៀន។
- សហគមន៍អាចមើលលទ្ធផល NAPLAN សាលារៀនជាមធ្យមនៅឯ **myschool.edu.au**

## តើទីណាដែលខ្ញុំអាចទទួលព័ត៌មានបន្ថែម?

ដើម្បីទទួលព័ត៌មានបន្ថែមអំពី NAPLAN៖

- ទាក់ទងសាលារៀនរបស់កូនលោកអ្នក
- ទាក់ទងអាជ្ញាធរគ្រប់គ្រងតេស្តក្នុងតំបន់លោកអ្នកនៅឯ **nap.edu.au/TAA**
- បើកមើល **nap.edu.au**

ដើម្បីទទួលព័ត៌មានអំពីរបៀបដែល ACARA មើលខុសត្រូវព័ត៌មានផ្ទាល់ខ្លួនសម្រាប់ NAPLAN សូមបើកមើល **nap.edu.au/naplanprivacy**